**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៤៣៣៣ព.ណ.....បល

ភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤

# សេចក្តីណែនាំ
## ស្តីពីការអនុវត្តន៍ខ្លឹមសារប្រកាសលេខ៣៦៥ ពណ.បល.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្មជូនដល់ ក្រុង ស្រុក ខណ្ឌគោលដៅ

ការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្ម គឺជាការអនុវត្តន៍តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការផ្តល់សេវាសាធារណៈ ក្នុងគោលបំណងបម្រើប្រជាពលរដ្ឋឲ្យបានកាន់តែប្រសើរ និងកាន់តែខិតទៅជិតប្រជាពលរដ្ឋនៅតាមមូលដ្ឋានចំណុះក្រុង ស្រុក ខណ្ឌ ធានាបាននូវភាពងាយស្រួល ឆាប់រហ័ស និងចំណាយតិចសម្រាប់អាជីវករ។ ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម គឺជាការទទួលស្គាល់បឋមនូវភាពស្របច្បាប់ជារូបវន្តបុគ្គល ក្នុងការប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ស្របទៅតាមគោលការណ៍ច្បាប់ជាធរមាន។

ដើម្បីឲ្យប្រកាសលេខ៣៦៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្មជូនដល់ស្រុក ក្រុង ខណ្ឌគោលដៅឲ្យទទួលបានលទ្ធផលល្អ ក្រសួងពាណិជ្ជកម្ម សូមធ្វើការណែនាំអនុវត្តអំពីវិធាន បែបបទ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម សម្រាប់អនុវត្តនៅការិយាល័យច្រកចេញចូលតែមួយ នៃក្រុង ស្រុក ខណ្ឌគោលដៅដូចខាងក្រោម៖

**I-ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម**

ក-គ្រប់អាជីវករទាំងអស់ ត្រូវមកស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ពីក្រុង ស្រុក ខណ្ឌគោលដៅ មានលក្ខខណ្ឌដូចខាងក្រោម៖

-អាជីវករដែលមានបំណងធ្វើ ឬកំពុងធ្វើសកម្មភាពទិញលក់ ឬធ្វើសេវាជាប្រចាំ ក្នុងគោលដៅស្វែងរកប្រាក់ចំណេញ ហើយមិនជាប់ពន្ធលើប្រាក់ចំណេញ

-អាជីវករ ដែលមានទីតាំងប្រកបមុខរបរជាអចិន្ត្រៃយ៍។

ខ-ក្រោយពីបានទទួលលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មរួចហើយ អាជីវករទាំងអស់ត្រូវគោរពតាមបញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មដែលមានជាធរមាន។

ក្នុងករណីមានការផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្ម ឈ្មោះអាជីវកម្ម ឬផ្លាស់ប្តូរអ្នកគ្រប់គ្រង អាជីវករត្រូវជូនដំណឹងមកការិយាល័យច្រកចេញចូលតែមួយ។



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ៖(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

II-ទម្រង់បែបបទនៃការស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម

បែបបទសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ត្រូវមានដូចខាងក្រោម៖

-ពាក្យសុំច្បាប់ប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម (មានគំរូស្រាប់) ចំនួន ០១ច្បាប់

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (បើជាជនបរទេស) ថតចម្លង ចំនួន ០១ច្បាប់

-ប័ណ្ណប៉ាតង់ ថតចម្លង (បើមាន) ចំនួន ០១ច្បាប់

-រូបថត ទំហំ៤ គុណ ៦ ចំនួន ០៣សន្លឹក

-កិច្ចសន្យា (មានគំរូស្រាប់) ចំនួន ០១ច្បាប់

III-ភារកិច្ចរបស់មន្ត្រីទទួលបន្ទុកការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម

-មន្ត្រីទទួលពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយ ត្រូវពិនិត្យលើទម្រង់បែបបទ ដែលអាជីវករបានមកដាក់ពាក្យស្នើសុំ ដើម្បីធានាភាពត្រឹមត្រូវគ្រប់គ្រាន់តាមសេចក្តីណែនាំ។ ក្នុងករណីដែលពិនិត្យឃើញថា ពាក្យស្នើសុំរបស់អាជីវករពុំទាន់បានបំពេញ ឬមិនចេះបំពេញតាមបែបបទកំណត់នេះ មន្ត្រីប្រចាំការត្រូវពន្យល់ណែនាំ និងជួយដល់អាជីវករ ក្នុងការបំពេញបន្ថែមលើពាក្យស្នើសុំនោះឲ្យបានគ្រប់គ្រាន់តាមលក្ខខ័ណ្ឌតម្រូវ។

-ក្នុងករណីដែលបែបបទនៃការដាក់ពាក្យស្នើសុំ គ្រប់គ្រាន់ ត្រឹមត្រូវតាមសេចក្តីណែនាំហើយនោះ មន្ត្រីទទួលប្រគល់ពាក្យស្នើសុំ ត្រូវចុះលេខចូលដោយបញ្ជាក់ថ្ងៃ ខែ ឆ្នាំ និងម៉ោង នៃការទទួលពាក្យ រួចចេញបង្កាន់ដៃទទួលពាក្យឲ្យអ្នកស្នើសុំ ហើយបញ្ជូនទៅមន្ត្រីទទួលបន្ទុកផ្នែកពាណិជ្ជកម្មជូរក្រោយ។

-មន្ត្រីទទួលបន្ទុកផ្នែកពាណិជ្ជកម្មប្រចាំក្រុង ស្រុក ខណ្ឌគោលដៅត្រូវប្រថាប់ត្រាចូលលើពាក្យស្នើសុំ ដោយមានបញ្ជាក់ថ្ងៃ ខែ ឆ្នាំ និងម៉ោងចូល ហើយត្រូវពិនិត្យសំណុំឯកសារពាក្យសុំ និងចុះអង្កេតពិនិត្យព្រមទាំងវាយតម្លៃផ្តល់យោបល់ជូនប្រធានការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យ និងសម្រេចមិនឲ្យហួសពីរយៈពេល ៧ថ្ងៃ នៃថ្ងៃធ្វើការ។

IV- ការបន្តសុពលភាពលិខិតអនុញ្ញាត

-លិខិតអនុញ្ញាតមានសុពលភាពរយៈពេល ០១ឆ្នាំ។ លិខិតអនុញ្ញាតដែលផុតសុពលភាព ចាំបាច់ត្រូវតែមកសុំការអនុញ្ញាតសារជាថ្មីពីការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌគោលដៅណាដែលគ្រឹះស្ថានអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម នោះតាំងនៅឲ្យបានមុនរយៈពេល១៥ថ្ងៃ។

ទទួលបានសេចក្តីណែនាំនេះ មន្ត្រីមានសមត្ថកិច្ចប្រចាំការិយាល័យច្រកចេញចូលតែមួយ នៃក្រុង ស្រុក ខណ្ឌគោលដៅ និងប្រជាពលរដ្ឋ អាជីវករ ដែលធ្វើសកម្មភាពអាជីវកម្ម សេវាកម្ម ក្នុងក្រុង ស្រុក ខណ្ឌគោលដៅ ត្រូវអនុវត្តទៅតាមខ្លឹមសារនៃសេចក្តីណែនាំនេះឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ស៊ុន ចាន់ថុល

ចម្លងជូន៖

-ក្រសួងមហាផ្ទៃ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

-សាលារាជធានី-ខេត្ត (ជូនជ្រាប)